**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

**សូមគោរពជូន**
**សម្ដេចពិជ័យសេនា ទៀ បាញ់**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**សម្ដេចពិជ័យសេនា ជាទីគោរពដ៏ខ្ពង់ខ្ពស់**!

ក្នុងឱកាសនៃពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ដែលនឹងឈានចូលមកដល់ខាងមុខនេះ តាងនាមថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ព្រមទាំងមន្ត្រីការទូតកម្ពុជាទាំងអស់ ដែលកំពុងបំពេញបេសកកម្មការទូតនៅបរទេស ខ្ញុំបាទ និងភរិយា សូមគោរពជូនពរ **សម្ដេចពិជ័យសេនា** ទទួលបាននូវសុខភាពល្អបរិបូរណ៍ ពលានុភាពមាំមួន បញ្ញាញាណភ្លឺថ្លាវាងវៃ ដើម្បីរួមចំណែកកសាងនូវសន្តិភាពជាតិ ស្ថិរភាពជាតិ ឯកភាពជាតិ សេដ្ឋកិច្ចជាតិ ការអភិវឌ្ឍជាតិលើគ្រប់វិស័យ ការពារលិទ្ធិប្រជាធិបតេយ្យ ព្រមទាំងរក្សាការពារបាននូវឯករាជ្យជាតិ និងបូរណភាពទឹកដី។

ឆ្លៀតក្នុងឱកាសដ៏នក្ខត្តឫក្សនេះ ខ្ញុំបាទ និងភរិយា សូមឧទ្ទិសបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក និងទេវតារក្សាទឹកដី នៃព្រះរាជាណាចក្រកម្ពុជា សូមជួយតាមថែរក្សាបីបាច់ **សម្ដេចពិជ័យសេនា** និង **លោកជំទាវ** ព្រមទាំងបុត្រា បុត្រី និងចៅប្រុស ចៅស្រី ជាទីស្រឡាញ់ទាំងអស់ សូមប្រកបនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្ដេចពិជ័យសេនា** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ និងភរិយា។

ថ្ងៃពុធ ៦កើត ខែចេត្រ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៩

**ប្រាក់ សុខុន** **ខេង សំវ៉ាដា**


អាសយដ្ឋានៈ លេខ ៣ វិថី សម្ដេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh